# គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និង យុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី ៣

## ករណីសិក្សា

**ស៊ីស៊ីចេប/ផ្នែក៖** *អគ្គនាយកដ្ឋានពន្ធនាគារ* **កាលបរិច្ឆេទ៖** *ខែ កុម្ភៈ ឆ្នាំ ២០១១*

**បុគ្គលដែលបំពេញបែបបទ៖** **បុគ្គលដែលត្រូវសម្ភាសន៍**

**ឈ្មោះ៖** *សូ វុទ្ធី* **ឈ្មោះ៖** *ប៊ី ប៊ុនសេង* **អាយុ៖** *៣៦ ឆ្នាំ*

**តួនាទី៖** *ប្រធានគម្រោងធ្វើសមាហរណកម្ម* **ភេទ៖** *ប្រុស*

*(អង្គការសម្ព័ន្ធមេត្រីភាពកម្ពុជា)* **ភូមិ៖** *ត្រពាំងពោរ* **ឃុំ៖** *ឪ លក*

**ស្រុក៖** *អង្គស្នួល* **ខេត្ត៖** *កណ្ដាល*

*អង្គការសម្ព័ន្ធមេត្រីភាពកម្ពុជា បានអនុវត្តកម្មវិធីធ្វើសមាហរណកម្មជនដែលធ្លាប់ជាប់ឃុំនៅពន្ធនាគារចាប់តាំងពីឆ្នាំ២០០៨ ក្នុងទិសដៅធ្វើអោយជនដែលធ្លាប់ជាប់ឃុំនៅពន្ធនាគារបានចូលទៅរស់នៅក្នុងសហគមន៍របស់ពួកគេវិញប្រកបដោយភាពជោគជ័យ។ កម្មវិធីនេះបានផ្សារភ្ជាប់ទៅនឹងកម្មវិធីកំណែទំរង់ពន្ធនាគាររបស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី ៣ និងបណ្ដាដៃគូអភិវឌ្ឍន៍ដទៃទៀតកំពុងសហការរួមគ្នាដើម្បីគាំទ្រកម្មវិធីទាំងនេះ។ ក្នុងឆ្នាំ ២០០៩ គម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ បានផ្ដល់ថវិកាតាមរយៈមូលនិធិគាំទ្រអង្គការសម្ព័ន្ធមេត្រីភាពកម្ពុជាដើម្បីអនុវត្តន៍កម្មវិធីនេះទូទាំងប្រទេស។*

ករណីសិក្សាខាងក្រោមនេះ គឺជាឧទាហរណ៍មួយនៃការគាំទ្ររបស់គម្រោង ស៊ី.ស៊ី.ចេប ដែលបានចូលរួមចំណែកធ្វើអោយសហគមន៍មានភាពរុងរឿង ប្រកបដោយបរិស្ថានសុវត្ថិភាព និងសន្តិសុខល្អ។

## ដំណើររឿង



លោក **ប៊ី ប៊ុនសេង** មានអាយុ ៣៦ ឆ្នាំជាកូនប្រុសទី២នៅក្នុងគ្រួសារដែលមានសមាជិកទាំង៧ ក្នុងនោះមានបងប្អូនប្រុសចំនួន ៥ នាក់ និងបងប្អូនស្រីចំនួន ២នាក់។ មុនពេលដែលគាត់ត្រូវបានឃាត់ខ្លួន លោក **ប៊ី ប៊ុនសេង** បានបើកហាងជួសជុលគ្រឿងអេឡិចត្រូនិចតូចមួយនៅក្នុងភូមិ។

លោក **អ៊ុយ សំអុល** ជាមន្ត្រីជាន់ខ្ពស់ផ្នែកសង្គមរបស់អង្គការសម្ព័ន្ធមេត្រីភាពកម្ពុជាបានបញ្ជាក់ថា លោក **ប៊ី ប៊ុនសេង** ចាប់តាំងពីពេលដែលប្រពន្ធរបស់គាត់បានរត់ចេញពីគាត់ គាត់បានក្លាយទៅជាបុរសប្រមឹកដែលបាត់បង់ភាពម្ចាស់ការចំពោះខ្លួន ហើយបានសេពគប់ជាមួយជនល្មើសនៅក្នុងមូលដ្ឋាន។ បន្ទាប់មក នគរបាលមូលដ្ឋានបានឃាត់ខ្លួនគាត់ដោយចោទប្រកាន់គាត់ពីបទពាក់ព័ន្ធទៅនឹងការលួចម៉ូតូមិត្តភ័ក្តិ។

ក្នុងឆ្នាំ ២០០៩ លោក **ប៊ី ប៊ុនសេង** ត្រូវបានផ្តន្ទាទោសអោយជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ ហើយត្រូវបានបញ្ជូនទៅកាន់ពន្ធនាគារខេត្តកណ្តាល។ លោកប្រធាន ពន្ធនាគារខេត្តកណ្តាលបានមានប្រសាសន៍ថា ពេលដែលនៅក្នុងពន្ធនាគារលោក **ប៊ី ប៊ុនសេង** មានអាក

ឬកិរិយាល្អ ហើយត្រូវបានចាត់ចំណាត់ថ្នាក់ក្នុងថ្នាក់សន្តិសុខទាប ហើយក្រោយមកត្រូវបានជ្រើសតាំងជាប្រធានថ្នាក់ក្នុងវគ្គបណ្តុះបណ្តាល។

**ការជួយអន្តរាគមន៍**

ក្នុងកំឡុងពេលទទួលទោសលោក **ប៊ី ប៊ុនសេង** បានស្នើសុំប្រធានពន្ធនាគារដើម្បីអនុញ្ញាតអោយគាត់បានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៃអង្គការសម្ព័ន្ធមេត្រីភាពកម្ពុជា ដែលមានការជួយឧបត្ថម្ភថវិកាពីគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី ៣ ក្នុងវគ្គបណ្តុះបណ្តាលអេឡិចត្រូនិចដែលមានរយៈពេល ៤ ខែ ។ លោក **ប៊ុនសេង** បានស្ម័គចិត្តចូលរួមក្នុងកម្មវិធីសមាហរណកម្មរបស់អង្គការសម្ព័ន្ធមេត្រីភាពកម្ពុជា នៅពេលដែលរូបគាត់ត្រូវបានដោះលែងចេញពីពន្ធនាគារ។ លោក **ប៊ី ប៊ុនសេង** ត្រូវបានបញ្ជូនទៅមណ្ឌលផ្ទើសមាហរណកម្មរបស់អង្គការសម្ព័ន្ធមេត្រីភាពកម្ពុជាដើម្បីផ្តល់ការគាំទ្របន្ថែក ដែលនៅទីនោះ គាត់ទទួលបានអាហារ កន្លែងស្នាក់នៅ និងការត្រួតពិនិត្យសុខភាពមុនពេលត្រឡប់មកផ្ទះ។

លោក **ប៊ី ប៊ុនសេង** បានបើកហាងជួសជុលគ្រឿងអេឡិចត្រូនិចមួយនៅខែឧសភា ឆ្នាំ ២០១០ ក្នុងភូមិកំណើតរបស់គាត់ ហើយគាត់អាចរកប្រាក់ចំណូលបានប្រហែលពី



១០.០០០ រៀល ទៅ ៣០.០០០ រៀលក្នុងមួយថ្ងៃ (៤.០០០រ ស្មើនិង ១ដុល្លារ)។

**ការផ្លាស់ប្តូរឥរិយាបថ**

លោក **ហ៊ុយ សំអុល** បានប្រាប់ថា សហគមន៍ និងគ្រួសាររបស់គាត់ មានចិត្តសប្បាយរីករាយណាស់ ដែលបានឃើញការផ្លាស់ប្តូររបស់

គាត់ ហើយ បានបញ្ជាក់ប្រាប់ថា ***ប៊ី ប៊ុនសេង*** ធ្លាប់ជាបុរសល្អម្នាក់ ប៉ុន្តែបន្ទាប់ពីពេលដែលប្រពន្ធគាត់បានរត់ចោលគាត់ គាត់ក៏មានការឈឺចិត្ត ហើយបានក្លាយខ្លួនជាបុរសប្រមឹកដែលបានសេពគប់ជាមួយមិត្តភ័ក្តិមិនល្អរហូតបណ្តាលអោយក្លាយខ្លួនទៅជាជនជាប់ឃុំ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីត្រូវបានដោះលែង គាត់បានរៀបអាពាហ៍ពិពាហ៍ និង បោះបង់ចោលនូវការសេពគ្រឿងស្រវឹង និងឈប់ពាក់ព័ន្ធជាមួយមិត្តភ័ក្តិចាស់ៗ ហើយប្រកបការងារយ៉ាងមមាញឹកដើម្បីដំណើរការហាងរបស់គាត់ និង មើលថែគ្រួសាររបស់គាត់បានយ៉ាងល្អ។ លោក ***ប៊ី ប៊ុនសេង*** មិនត្រឹមតែបើកហាងខ្លួនឯងនោះទេ ហើយថែមទាំងបើកវគ្គបណ្តុះបណ្តាលផ្នែកអេឡិចត្រូនិចដល់អ្នកភូមិ និង ព្រះសង្ឃនៅក្នុងសហគមន៍ទៀតផងដើម្បីរកប្រាក់ចំណូលបន្ថែម។

*អ៊ំស្រី* ***ជា សៅ*** *អាយុ៦៤ឆ្នាំដែលជាចាស់ទុំនៅក្នុងភូមិជាមួយគ្នានោះបានប្រាប់ថា អ្នកភូមិបានគាំទ្រ និងចូលចិត្តសេវារបស់ហាងគាត់ខ្លាំងណាស់។*

*លោក* ***ផៃ ភឿន*** *ដែលមានអាយុ ៣៩ ឆ្នាំបានបញ្ជាក់ប្រាប់ថា គាត់មានចិត្តសប្បាយរីករាយណាស់ដែលបានឃើញការផ្លាស់ប្តូររបស់លោក* ***ប៊ី ប៊ុនសេង***។ *ឥឡូវនេះ គាត់ក៏ជាអតិថិជនប្រចាំហាងរបស់លោក* ***ប៊ី ប៊ុនសេង*** *ផងដែរ។*

*លោក* ***ប៊ី ប៊ុនសេង*** *បានអំពាវនាវអោយកម្មវិធីនេះបន្តផ្តល់ការគាំទ្រដល់អ្នកដទៃដូចរូបគាត់ដែរ៕*